ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភាឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ក្របខ័ណ្ឌគតិយុត្ត សម្រាប់ផ្តល់ធនធានហិរញ្ញវត្ថុមួយចំណែកប្រកបដោយសមធម៌ ចីរភាព និងអាចព្យាករណ៍បានដល់រដ្ឋបាលក្រុង ស្រុក ដើម្បីជួយទ្រទ្រង់និងអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិក្រុង ស្រុក ក្នុងការផ្តល់មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌពីថវិកាជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់រួមចំណែកក្នុងការអនុវត្តចំណាយបម្រើឱ្យសកម្មភាពទាំងឡាយដូចតទៅ ៖

- ការបំពេញភារកិច្ចតាមផ្លូវច្បាប់
- ការបំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា។

## ជំពូកទី២

## ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិក្រុង ស្រុក

**មាត្រា ៤.-**

ប្រភពធនធាននៃមូលនិធិក្រុង ស្រុករួមមាន ៖

- ការចូលរួមចំណែកពីចំណូលចរន្តនៃថវិការដ្ឋ
- ការរួមចំណែកពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ និង
- ការចូលរួមធនធានពីប្រភពផ្សេងៗទៀតដែលកំណត់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

**មាត្រា ៥.-**

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុកត្រូវកំណត់សម្រាប់ថេរៈវេលាចំនួនបីឆ្នាំ

លើមូលដ្ឋានក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃថវិកាទូទៅរបស់រដ្ឋ។

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុក សម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ មានដូចខាងក្រោម៖

- សម្រាប់ឆ្នាំថវិកា២០១២មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១១
- សម្រាប់ឆ្នាំថវិកា២០១៣ មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័តនៅឆ្នាំ២០១២ និង
- សម្រាប់ឆ្នាំថវិកា២០១៤ មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័តនៅឆ្នាំ២០១៣។

**មាត្រា ៦.-**

ក្នុងករណីមានការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ ឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឬសប្បុរសជននានាតាមរយៈប្រព័ន្ធថវិការដ្ឋដើម្បីជួយទ្រទ្រង់ការអភិវឌ្ឍមូលដ្ឋានក្រុង ស្រុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាត់នីតិវិធីបង់ចំណូលថវិការដ្ឋតាមរយៈរតនាគារជាតិគ្រង់តែម្តង។ ព្រមជាមួយនេះ ឥណទានបន្ថែមដែលមានទឹកប្រាក់ដូចគ្នាទៅនឹងចំណូលដែលបានបង់ចូលថវិការដ្ឋនេះ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវបានផ្ទេរចូលគណនីដោយឡែកនៃមូលនិធិក្រុង ស្រុក តាមរយៈអាណត្តិឧបត្ថម្ភកធនស្របតាមគោលដៅរបស់ភាគី ឬដៃគូអភិវឌ្ឍន៍។

**មាត្រា ៧.-**

ធនធាននៃមូលនិធិក្រុង ស្រុកត្រូវបានចាត់ចែង និងគ្រប់គ្រងតាមរយៈគណនីដោយឡែកមួយនៅរតនាគារជាតិ។ គណនីនេះត្រូវឆ្លុះបញ្ចាំងនូវរាល់ប្រតិបត្តិការចំណូលដែលបានមកពីគ្រប់ប្រភពធនធានទាំងអស់នៃមូលនិធិក្រុង ស្រុក ដូចបានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ និងប្រតិបត្តិការចំណាយដែលបានផ្ទេរពីមូលនិធិក្រុង ស្រុកប្រចាំឆ្នាំសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលក្រុង ស្រុកនីមួយៗដូចបានកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។

សមតុល្យចុងឆ្នាំនៃគណនីមូលនិធិក្រុង ស្រុកត្រូវបានយោងទៅដើមឆ្នាំបន្ទាប់។

**មាត្រា ៨.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រប់គ្រងមូលនិធិក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំវិភាជន៍ធនធានមូលនិធិក្រុង ស្រុកជូនដល់រដ្ឋបាលក្រុង ស្រុកនីមួយៗដូចដែលបានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ
- ជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុកអំពីចំនួនធនធានមូលនិធិក្រុង ស្រុកដែលត្រូវទទួលបានពីការវិភាជន៍ប្រចាំឆ្នាំមុនពេលរៀបចំថវិកា និងធនធានមូលនិធិដែលរដ្ឋបាលក្រុង ស្រុកត្រូវទទួលបានពីការវិភាជន៍សម្រាប់រយៈពេលមធ្យម និង

- រៀបចំរបាយការណ៍នៃការអនុវត្តមូលនិធិក្រុង ស្រុក ប្រចាំខែ ប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំនៃការអនុវត្តមូលនិធិក្រុង ស្រុក ជូនរាជរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៩.-**

ក្រោយពីបានសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវ ៖

- ពិនិត្យ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូរនានា ដែលត្រូវកែសម្រួលពាក់ពន្ធ័នឹងគោលបំណង វិធាន និងគោលការណ៍ផ្សេងៗនៃមូលនិធិក្រុង ស្រុក
- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីកម្រិតជាភាគរយនៃចំណែកចូលរួមពីថវិការដ្ឋទៅក្នុងធនធានមូលនិធិក្រុង ស្រុក
- កំណត់គោលដៅនានាដើម្បីកៀរគរធនធានពីខាងក្រៅចូលក្នុងធនធានមូលនិធិក្រុង ស្រុក
- កំណត់រូបមន្ត លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រជាក់លាក់ ដើម្បីបែងចែកធនធាននៃមូលនិធិក្រុង ស្រុក
- អនុញ្ញាតឱ្យមានការវាយតម្លៃឯករាជ្យលើការអនុវត្តមូលនិធិក្រុង ស្រុក ដោយអាជ្ញាធរសវនកម្មមានសមត្ថកិច្ច
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីដំណើរការមូលនិធិក្រុង ស្រុករៀងរាល់៦ខែ
- ធ្វើកិច្ចអន្តរាគមន៍លើការផ្ទេរធនធានមូលនិធិក្រុង ស្រុកក្នុងករណីចាំបាច់។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងតំណាងក្រុមប្រឹក្សាក្រុង ស្រុកត្រូវពិភាក្សាពិគ្រោះយោបល់នូវរាល់បញ្ហាពាក់ព័ន្ធនឹងគោលនយោបាយ និងប្រតិបត្តិផ្សេងៗលើការអនុវត្តមូលនិធិក្រុង ស្រុក។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីកំណត់នីតិវិធីនិងបែបបទលើការជ្រើសរើសតំណាងក្រុមប្រឹក្សាក្រុង ស្រុក និងចូលរួមពិភាក្សាពិគ្រោះយោបល់ក្នុងការរៀបចំគោលនយោបាយដែលពាក់ព័ន្ធដល់ការអនុវត្តមូលនិធិក្រុង ស្រុក។

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវមានតួនាទីជាអ្នកទទួលខុសត្រូវផ្ទាល់ ក្នុងការជួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវ ៖

- តាមដានការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកលើការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក
- រាយការណ៍ជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុកដោយរដ្ឋបាលក្រុង ស្រុក
- ស្នើកិច្ចអន្តរាគមន៍ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការផ្ទេរធនធានមូលនិធិក្រុង ស្រុកទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងករណីចាំបាច់។

## ជំពូកទី៣
## ការបែងចែក ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក

**មាត្រា ១១.-**

ធនធានដែលវិភាជន៍ប្រចាំឆ្នាំទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវផ្អែកតាមរូបមន្តសមស្របដើម្បីធានាសមធម៌ និងប្រកបដោយតម្លាភាព។ លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រដែលប្រើក្នុងរូបមន្តដើម្បីវិភាជន៍ធនធាន ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយជាសាធារណៈ។ ធនធានមូលនិធិដែលបានវិភាជន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុក គឺជាចំណែកមួយនៃគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រខាងលើនេះ ត្រូវបានកំណត់សម្រាប់រយៈពេលយ៉ាងតិចបីឆ្នាំ។ ការកែសម្រួលលក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រត្រូវតែធ្វើឡើងដោយផ្អែកតាមលក្ខណៈបច្ចេកទេសសមស្រប ឬក្រោមហេតុផលនៃយុត្តិកម្មគោលនយោបាយ ដើម្បីធានាបាននូវសមធម៌នៃការវិភាជន៍ធនធានដល់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

**មាត្រា ១២.-**

ធនធានមូលនិធិក្រុង ស្រុក ត្រូវចែកចេញជាពីរសមាសភាគដូចខាងក្រោម ៖

- សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និង
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ទំហំធនធាននៃសមាសភាគនីមួយៗនៃមូលនិធិក្រុង ស្រុកត្រូវកំណត់ដូចខាងក្រោម ៖

ក). ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ ត្រូវបានកំណត់ដោយផ្អែកលើឯកតា រង្វាស់ និងនិយាមដូចខាងក្រោម ៖

- ចំនួនសរុបនៃសមាជិកក្រុមប្រឹក្សាក្រុងស្រុក និងប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ចំនួនសរុបនៃអភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក និងប្រាក់បៀវត្សសម្រាប់ប្រភេទនីមួយៗ និង

- គម្រោងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗទៀត មិនឱ្យលើសពី២៨ភាគរយនៃធនធានមូលនិធិសរុប *ដក* ចំនួនសរុបប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់អភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។

ខ). ទំហំធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងធនធានវិភាជន៍សរុប *ដក* ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ។

**មាត្រា ១៣.-**

ធនធាននៃសមាសភាគទាំងពីរនៃមូលនិធិក្រុង ស្រុក ត្រូវបានបែងចែកទៅរដ្ឋបាលក្រុង ស្រុកនីមួយៗស្របតាមវិធានដូចខាងក្រោម ៖

១. ធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅត្រូវបានវិភាជន៍ទៅរដ្ឋបាលក្រុង ស្រុកនីមួយៗដោយអនុលោមតាមនិយាមដូចខាងក្រោម ៖

ក). ចំណាយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាក្រុង ស្រុក

ខ). ចំណាយប្រាក់បៀវត្សរបស់អភិបាល អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក

គ). ចំណាយប្រាក់បៀវត្សរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុក ផ្អែកតាមចំនួនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដែលកំណត់ដោយក្រសួងមហាផ្ទៃ

ឃ). ធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗត្រូវបែងចែកទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

- ចំណែកស្មើគ្នាមានចំនួន៤០ភាគរយ ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ
- សមាជិកក្រុមប្រឹក្សាមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- គណៈអភិបាលមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាសភាពគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- មន្ត្រីបុគ្គលិកមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនមន្ត្រីបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ។

២. ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានត្រូវបានវិភាជន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗតាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

ក). ចំណែកស្មើគ្នាជាមូលដ្ឋានមានចំនួន៤០ភាគរយ ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ

ខ). ប្រជាពលរដ្ឋមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជន

នៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

គ). សន្ទស្សន៍ភាពក្រីក្រមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ និង

ឃ). ឃុំ សង្កាត់មានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុកនីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

លក្ខណៈវិនិច្ឆ័យ និងចំនួនភាគរយនៃសន្ទស្សន៍នីមួយៗសម្រាប់ធ្វើការបែងចែកធនធានឱ្យសមាសភាគអភិវឌ្ឍន៍មូលដ្ឋានអាចត្រូវបានពិនិត្យ និងកែលម្អឡើងវិញនាពេលមួយសមស្របដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ។

**មាត្រា ១៤.-**

រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់ធនធានដែលផ្ទេរពីមូលនិធិក្រុង ស្រុកដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយ ចំណែកណាមួយដូចខាងក្រោមនេះបាន លុះត្រាតែចំណាយទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិកាក្រុង ស្រុកដែលបានអនុម័ត និងមិនផ្ទុយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងច្បាប់និងលិខិតបទដ្ឋាននានាដទៃទៀតដែលមានជាធរមាន។

១. ការប្រើប្រាស់ធនធានមូលនិធិនៃសមាភាគរដ្ឋបាលទូទៅ ៖

ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ចប្រតិបត្តិការរដ្ឋបាលក្រុង ស្រុក

ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍន៍ ឬលទ្ធកម្មលើអចលនទ្រព្យ ដូចជាអគារ បរិក្ខារការិយាល័យ គ្រឿងសង្ហារិម មធ្យោបាយដឹកជញ្ជូនសម្រាប់ប្រើប្រាស់ក្នុងបុព្វហេតុរដ្ឋបាល។

២. ការប្រើប្រាស់ធនធានមូលនិធិនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ៖

ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាមូលដ្ឋាន កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននិងបរិក្ខារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់សេវាទាំងនោះ។

ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។

**មាត្រា ១៥.-**

ផ្អែកលើមូលនិធិដែលត្រូវផ្ទេរប្រចាំឆ្នាំទៅឱ្យរដ្ឋបាលក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបោះផ្សាយអាណត្តិផ្ទេរពីគណនីថវិការដ្ឋ ទៅគណនីដោយឡែករបស់មូលនិធិក្រុង ស្រុកនៅរតនាគារជាតិតាមការកំណត់ដូចខាងក្រោម ៖

- ៥០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែឧសភា
- ៨០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែសីហា

- ១០០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែតុលា។

ការផ្ទេរធនធានមូលនិធិក្រុង ស្រុកជូនទៅរដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវធ្វើឡើងជាបួនដំណាក់ ដោយកំណត់ប្រចាំត្រីមាសនីមួយៗ។ នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបញ្ជាផ្ទេរចំណាយ ចំនួនមួយភាគបួន(១/៤)នៃមូលនិធិប្រចាំឆ្នាំរបស់ក្រុងស្រុកនីមួយៗដោយស្វ័យប្រវត្តិ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលក្រុង ស្រុកត្រូវធ្វើសំណើសុំផ្ទេរមូលនិធិមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ នៅដើមខែទីបីនៃត្រីមាសមុន ដើម្បីធ្វើការផ្ទៀងផ្ទាត់ល័ក្ខខ័ណ្ឌនានានៃការផ្ទេរធនធានមូលនិធិក្រុង ស្រុកដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងរបាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ដោយមានឯកសារគាំទ្រជាមូលដ្ឋាន។

នីតិវិធីក្នុងការផ្ទៀងផ្ទាត់នៃការបំពេញល័ក្ខខ័ណ្ឌសម្រាប់ការផ្ទេរទម្រង់របាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងទម្រង់របាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ និងឯកសារគាំទ្រជាមូលដ្ឋានខាងលើនេះត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

នៅក្នុងឆ្នាំ២០១២ ក្នុងករណីដែលរដ្ឋបាលក្រុង ស្រុកពុំទាន់មានថវិកាផ្ទាល់របស់ខ្លួន ការផ្ទេរមូលនិធិទៅឱ្យក្រុង ស្រុកនីមួយៗត្រូវបានកត់ត្រានៅក្នុងគម្រោងថវិការបស់ខេត្តសាមីដោយលម្អិតទៅតាមក្រុង ស្រុកនីមួយៗ និងត្រូវបានអភិបាលនៃគណៈអភិបាលខេត្តធ្វើប្រតិភូកម្មជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុកនីមួយៗ ជាអាណាប័កផ្ទេរសិទ្ធិទាំងចំណូល ទាំងចំណាយនៅពេលដំណើរការអនុវត្តថវិកាដែលមានគណនីប្រាក់បញ្ញើថវិកាដោយឡែកពីគណនីប្រាក់បញ្ញើថវិការបស់ខេត្តសាមី។

នៅក្នុងឆ្នាំ២០១២ ប្រសិនបើមានការចូលរួមធនធានពីដៃគូអភិវឌ្ឍន៍ទៅក្នុងមូលនិធិក្រុង ស្រុកធនធាននោះនឹងត្រូវបានវិភាជន៍ និងផ្ទេរជូនក្រុង ស្រុកត្រង់ចូលទៅគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលក្រុង ស្រុកដើម្បីអនុវត្តដោយផ្ទាល់តែម្តង។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងអភិបាលក្រុង ស្រុកទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>កន្លែងទទួល</u> ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ